Khmer/ខ្មែរ

ប្រជាមតិ ឆ្នាំ 2023

# ឈប់ ហើយ ពិចារណា

**ពិនិត្យមើលប្រភព**
នៅក្នុងការធ្វើប្រជាមតិនាពេលខាងមុខនេះ

ក្នុងអំឡុងពេលធ្វើប្រជាមតិ អ្នកអាចប្រទះឃើញព័ត៌មានដែលគ្មានភស្តុតាងគាំទ្រ បាត់បរិបទ ឬថែមទាំងមានការបំភាន់ដោយចេតនាទៀតផង។ ដើម្បីឱ្យបានជ្រាបច្បាស់លាស់ ចូរធ្វើជាអ្នកចូលចិត្តរិះគន់នៅពេលមើល ឬអានព័ត៌មាន ហើយគិតថាតើព័ត៌មាននោះត្រឹមត្រូវ ហើយពិតឬក៏អត់។

## យុទ្ធវិធីផ្សព្វផ្សាយព័ត៌មានខុស

ការផ្សព្វផ្សាយព័ត៌មានខុស គឺជាការផ្សព្វផ្សាយព័ត៌មានមិនពិតដោយចេតនា ដែលបង្កើតឡើងដើម្បីបំភាន់ និងដាក់ឥទ្ធិពលលើមតិសាធារណៈដោយចេតនា ហើយការផ្សព្វផ្សាយព័ត៌មានខុសមិនរីករាលដាលដោយខ្លួនឯងនោះទេ។ មនុស្សដែលព្យាយាមផ្សព្វផ្សាយព័ត៌មានមិនពិត អាចប្រើយុទ្ធវិធីមួយចំនួនខាងក្រោមដើម្បីព្យាយាមនិងបំភាន់អ្នកដោយចេតនា

### គ្រាន់តែសួរសំណួរប៉ុណ្ណោះ

មនុស្សអាចសួរសំណួរដោយចេតនា ដើម្បីដាក់ការសង្ស័យលើអ្វីមួយដោយមិនផ្តល់ភស្តុតាងណាមួយសោះ។ ទោះបីជាសំណួរភាគច្រើនដែលសួរនោះគឺស្របច្បាប់ក៏ដោយ ចូរឃ្លាំមើលសំណួរនានាដែលសួរដោយមិនស្មោះត្រង់ ឬអំពីស្ថានភាពដែលមិនទំនងទាល់តែសោះ។ ឈប់ ហើយពិចារណា ថាហេតុអ្វីបានជាគេកំពុងសួរសំណួរនេះ។

### ភាសាអារម្មណ៍

ភាសាម៉ឺងម៉ាត់ដែលរំឭកពីអារម្មណ៍អវិជ្ជមានដូចជាកំហឹង ឬការភ័យខ្លាច អាចធ្វើឱ្យមាតិការីករាលដាលកាន់តែងាយស្រួល។ ប្រសិនបើអ្នកឃើញអ្វីមួយ ដែលធ្វើឱ្យអ្នកមានអារម្មណ៍ឆ្លើយតបខាងផ្លូវចិត្តខ្លាំងក្លា សូមឈប់ ហើយពិចារណាពីមូលហេតុ។

### ការជ្រើសរើសអ្វីមួយដើម្បីទទួលបានអត្ថប្រយោជន៍ (Cherry-picking)

ការជ្រើសរើសអ្វីមួយដើម្បីទទួលបានអត្ថប្រយោជន៍ (cherry-picking) កើតមានឡើងនៅពេលដែលព័ត៌មានត្រូវបានផ្តល់ឱ្យដោយគ្មានបរិបទ ដូចជារូបថតអេក្រង់ ឬស្ថិតិ ដោយមិនយោងទៅប្រភពដើមរបស់វា។

## តួនាទីរបស់អ្នកជាអ្នកបោះឆ្នោត

ច្បាប់ប្រជាមតិមិនគ្រប់គ្រងការពិតនៅក្នុងការទំនាក់ទំនង ឬការផ្សព្វផ្សាយពាណិជ្ជកម្មទេ។ សូមចំណាយពេលពិចារណា ថាតើព័ត៌មាននោះគឺ៖

**អាចទុកចិត្តបាន**

**តើវាមកពីប្រភពដែលអាចទុកចិត្តបាន ឬដែលអាចទទួលស្គាល់បានឬទេ?**

តើអ្នកដឹងពីប្រភពនៃព័ត៌មាននោះទេ? តើវាមកពីប្រព័ន្ធផ្សព្វផ្សាយដែលមានការទទួលស្គាល់ ឬគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមជាផ្លូវការឬទេ? ប្រសិនបើអ្នកមិនប្រាកដទេ សូមពិនិត្យមើលថាតើគណនីនោះត្រូវបានបង្កើតឡើងថ្មីៗ ឬប្រសិនបើវាមានការបង្ហោះផ្សេងទៀត។

**បច្ចុប្បន្ន**

**តើគេបោះពុម្ពវានៅពេលណា?**

ដោយសារតែការបង្ហោះ/អត្ថបទត្រូវបានចែករំលែកនៅថ្ងៃនេះ មិនមានន័យថាវាបច្ចុប្បន្ននោះទេ។ ត្រូវពិនិត្យប្រភពដើម និងកាលបរិច្ឆេទបោះពុម្ពជានិច្ច។ ការបង្ហោះ/អត្ថបទចាស់ៗដែលប្រហែលជាមិនមានភាពត្រឹមត្រូវទៀត អាចត្រូវបានចែករំលែក ដើម្បីធ្វើឱ្យវាមើលទៅហាក់ដូចជាព័ត៌មានថ្មីៗ។

## តួនាទីរបស់ AEC

AEC គឺជាទីភ្នាក់ងារឯករាជ្យដែលត្រូវបានផ្តល់ភារកិច្ចឱ្យគ្រប់គ្រងការធ្វើប្រជាមតិ។ តួនាទីរបស់ AEC គឺ៖

### ផ្តល់ព័ត៌មានដែលអាចទុកចិត្តបានអំពីដំណើរការធ្វើប្រជាមតិ

AEC នឹងផ្តល់ភាពងាយស្រួលដល់ការទទួលបានព័ត៌មាន ទាក់ទងនឹងរបៀបចុះឈ្មោះ ឬបោះឆ្នោត តាមរយៈយុទ្ធនាការផ្សព្វផ្សាយពាណិជ្ជកម្ម គេហទំព័រ មជ្ឈមណ្ឌលទំនាក់ទំនង និងគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមរបសយើង។ ប្រសិនបើមានព័ត៌មានមិនត្រឹមត្រូវអំពីដំណើរការទាំងនេះ AEC នឹងចាត់វិធានការដើម្បីកែតម្រូវកំណត់ត្រានោះ។ នៅខាងក្រៅដំណើរការទាំងនេះ - AEC មិនមានតួនាទីណាមួយ ក្នុងការត្រួតពិនិត្យភាពត្រឹមត្រូវនៃការទំនាក់ទំនងប្រជាមតិទេ។

### ស៊ើបអង្កេតការអនុញ្ញាតនៃការទំនាក់ទំនងប្រជាមតិ

ការទំនាក់ទំនងប្រជាមតិមួយចំនួន ត្រូវបានទាមទារឱ្យមានការអនុញ្ញាត ដើម្បីជួយអ្នកឱ្យបានដឹងពីប្រភពនៃព័ត៌មាននោះ។

### សម្ភារៈយុទ្ធនាការ Yes និង No

ទោះបីជា AEC ទទួលខុសត្រូវក្នុងការចេញខិតប័ណ្ណប្រជាមតិ ដែលនឹងមានព័ត៌មានពីយុទ្ធនាការ Yes និង No ជាផ្លូវការក៏ដោយ AEC មិនមានតួនាទីក្នុងការគ្រប់គ្រងភាពត្រឹមត្រូវនៅក្នុងការទំនាក់ទំនងទាំងនេះទេ។

aec.gov.au/translated 1300 720 134

AEC Australian Electoral Commission

AEC23/1804

ផ្តល់សិទ្ធិអនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត ទីក្រុង Canberra
Authorised by the Electoral Commissioner, Canberra